# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

៚៚៚✸៙៙

## កិច្ចព្រមព្រៀងរវាង
## រោងចក្រ ខេមបូ យូនីសូល អិលធីឌី ជាមួយនិង
## កម្មករនិយោជិតទាំងអស់ ស្តីអំពីការព្យួរកិច្ចសន្យាការងារ និង នីតិវិធីទូទាត់

ដោយមើលឃើញថារោងចក្រខ្វះការបញ្ជាទិញ ដែលធ្វើអោយរោងចក្រមិនមានការងារអោយកម្មករនិយោជិតធ្វើគ្រប់គ្រាន់ កម្មករនិយោជិតទាំងអស់ ដែលតំណាងដោយសហជីព និងប្រតិភូបុគ្គលិក ឯកភាពគ្នាជាមួយរោងចក្រ ក្នុងការព្យួរកិច្ចសន្យាការងារ ដែលចែកចេញជាពីរវគ្គ និងក្នុងការទូទាត់ប្រាក់ ឧបត្ថម្ភដូចខាងក្រោមៈ

១- វគ្គទី១ ត្រូវព្យួរកិច្ចសន្យាការងារចាប់ពីថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០២០ រហូតដល់ ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២០។ សំរាប់អំឡុងពេលនៃការព្យួរនេះ កម្មករនិយោជិតមិនទទួលបានប្រាក់ឈ្នួលទេ ប៉ុន្តែរោងចក្រផ្តល់ប្រាក់ឧបត្ថម្ភ ចំនួន២០ ដុល្លាអាមេរិក ដល់កម្មករនិយោជិតម្នាក់ៗ ដោយផ្តល់ជូនតាមរយៈគណនេយ្យ វីង (Wing) របស់កម្មករនិយោជិត ដោយរួមជាមួយនិងប្រាក់ឈ្នួល លើកទី១នៃខែមិថុនា របស់កម្មករនិយោជិត ដែលត្រូវផ្តល់ជូននៅចន្លោះថ្ងៃទី១៨ និង ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២០។

២- វគ្គទី២ ត្រូវព្យួរកិច្ចសន្យាការងារចាប់ពីថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២០ រហូតដល់ ថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០២០។ សំរាប់អំឡុងពេលនៃការព្យួរនេះ កម្មករនិយោជិតមិនទទួលបានប្រាក់ឈ្នួលទេ ប៉ុន្តែរោងចក្រផ្តល់ប្រាក់ឧបត្ថម្ភ ចំនួន២០ ដុល្លាអាមេរិក ដល់កម្មករនិយោជិតម្នាក់ៗ ដោយផ្តល់ជូនតាមរយៈគណនេយ្យ វីង (Wing) របស់កម្មករនិយោជិត ដោយរួមជាមួយនិងប្រាក់ឈ្នួល លើកទី២នៃខែមិថុនា របស់កម្មករនិយោជិត ដែលត្រូវផ្តល់ជូននៅចន្លោះថ្ងៃទី០៥ និង ថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០២០។

៣- រោងចក្រនឹងរៀបចំសំណើសុំព្យួរកិច្ចសន្យាការងារ របស់កម្មករនិយោជិតនិងឯកសារដែលពាក់ព័ន្ធផ្សេងទៀត ដើម្បីគោរពជូនទៅក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ តាមរយៈមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកណ្តាល ដើម្បីទទួលបានការអនុញ្ញាតព្យួរកិច្ចសន្យាការងារ ក៏ដូចជា ដើម្បីបងប្អូនកម្មករនិយោជិតអាចទទួលបានប្រាក់ឧបត្ថម្ភរបស់រាជរដ្ឋាភិបាល។

៤- សំរាប់ប្រាក់រង្វាន់ការងារទៀងទាត់ ប្រាក់ឧត្ថម្ភការធ្វើដំណើរនិងស្នាក់នៅ និងប្រាក់រង្វាន់ផ្ទាល់ខ្លួន របស់បងប្អូនកម្មករនិយោជិត សំរាប់ខែមិថុនា និង ខែកក្កដា ដែលមានការព្យួរកិច្ចសន្យាការងារភាគខ្លះនៃខែនោះ រោងចក្រនឹងផ្តល់ជូនតាមអត្រាសមាមាត្រនឹងចំនួនថ្ងៃដែលបានធ្វើការងារជាក់ស្តែង (ពោលគឺមិនផ្តល់ជូន ចំពោះអំឡុងពេលនៃការព្យួរកិច្ចសន្យាការងារទេ)។

**បញ្ជាក់៖** កិច្ចព្រមព្រៀងនេះមានប្រសិទ្ធិភាពចំពោះ កម្មករនិយោជិតទាំងអស់របស់ រោងចក្រ ខេមបូ យូនីសូល អិលធីឌី ជាមួយនិង និយោជកនៃរោងចក្រ ខេមបូ យូនីសូល អិលធីឌី ចាប់ពីពេល ចុះហត្ថលេខានេះ តទៅ។

ធ្វើនៅខេត្តកណ្តាល ថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២០

**តំណាងភាគីកម្មករនិយោជិត**
**ថ្នាក់ដឹកនាំសហជីព និង ប្រតិភូបុគ្គលិក**

**តំណាងភាគីរោងចក្រ**
**ជួសនាយកក្រុមហ៊ុន**
**នាយករោងចក្រ**

ព្រះរាជាណាចក្រកម្ពុជា
ក្រុមហ៊ុន
ខេមបូ យូនីសូល អិលធីឌី
CAMBO UNISOLL LTD.
KINGDOM OF CAMBODIA

LEE JAE HO